ព្រឹទ្ធសភា
អគ្គលេខាធិការដ្ឋាន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍
# ស្តីពី
# លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែមករា និងទិសដៅការងារខែកុម្ភៈ ឆ្នាំ២០២១

នៅក្នុងខែមករានេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានខិតខំបំពេញការងារយ៉ាងសកម្ម និងមមាញឹកលើគ្រប់ការដ្ឋាន ដើម្បីផ្តល់សេវាជូនថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា ក្នុងការអនុវត្តមុខងាររបស់ខ្លួនបានល្អប្រសើរដោយទទួលបានលទ្ធផលសំខាន់ៗដូចខាងក្រោម៖

**I-លទ្ធផលការងារសម្រេចបានលើមុខងារទាំង៥៖**

**១- មុខងារនីតិកម្ម**

- បានរៀបចំចាត់ចែងប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាចំនួន០១លើក ដើម្បីពិនិត្យ និងសម្រេចលើ៖

១-របាយការណ៍ទូទាត់ថវិការបស់ព្រឹទ្ធសភាឆ្នាំ២០២០

២-គោលការណ៍បែងចែក និងប្រើប្រាស់ថវិកាព្រឹទ្ធសភាឆ្នាំ២០២១

- បានទទួលព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សារាចរណែនាំ ប្រកាស សេចក្តីសម្រេច សេចក្តីជូនដំណឹង របាយការណ៍ និងលិខិតផ្សេងៗចំនួន៣៥១ច្បាប់

- បានធ្វើកំណត់បង្ហាញព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្តីសម្រេច សារាចរណែនាំ ប្រកាស របាយការណ៍ និងលិខិតផ្សេងៗចំនួន៣៩ច្បាប់

- បានធ្វើបច្ចុប្បន្នភាពគេហទំព័រ (Laws.gov.kh) ប្រមូលព័ត៌មានទាក់ទងនឹងច្បាប់ អនុក្រឹត្យ ព្រះរាជក្រឹត្យ និងច្បាប់ដែលបានធ្វើវិសោធនកម្ម និងអនុម័តរួចៗ

**២- មុខងារតាមដានការអនុវត្តច្បាប់ និងគោលនយោបាយនានា**

- បានរៀបចំបែបបទ ផ្តល់សេវា និងអមដំណើរសមាជិកព្រឹទ្ធសភា អញ្ជើញជួបពិភាក្សាការងារជាមួយមន្ត្រីជំនាញការិយាល័យអប់រំ យុវជន និងកីឡា ខណ្ឌចំការមន ដើម្បីស្តាប់របាយការណ៍អំពីការវិវត្តរីកចម្រើនថ្មី បញ្ហាប្រឈម និងវិធានការនានា នៅសាលប្រជុំការិយាល័យអប់រំ



វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (855 23) 211 441, 211 442, 211 443 ទូរសារ: (855 23) 211 446, E-mail: oum_sarith@camnet.com.kh

ខណ្ឌចំការមន រាជធានីភ្នំពេញ

- បានរៀបចំបែបបទ ផ្តល់សេវា និងអមដំណើរសមាជិកព្រឹទ្ធសភា អញ្ជើញចុះបំពេញបេសកកម្មជាមួយប្រតិភូក្រសួងបរិស្ថាន ដើម្បីពិភាក្សាលើករណីប្រជាពលរដ្ឋដែលកាន់កាប់ និងអាស្រ័យផលនៅក្នុងដែនជំរកសត្វព្រៃភ្នំត្នោត និងភ្នំពក នៅឃុំស្តៅ ស្រុកសង្គមថ្មី ខេត្តព្រះវិហារ។

**៣- មុខងារតំណាង**

- បានផ្តល់សេវា និងអមដំណើរថ្នាក់ដឹកនាំព្រឹទ្ធសភា អញ្ជើញចុះជួបសំណេះសំណាល សាកសួរសុខទុក្ខកងកម្លាំង និងប្រជាពលរដ្ឋ ជួបពិភាក្សាការងារជាមួយអាជ្ញាធរមូលដ្ឋាន ចុះពិនិត្យការដ្ឋានសាងសង់សមិទ្ធផលនានា នាំយកសម្ភារបរិក្ខារ និងបច្ច័យមួយចំនួនទៅប្រគេនព្រះសង្ឃ ព្រមទាំងអញ្ជើញជាអធិបតី និងចូលរួមក្នុងពិធីផ្លូវការផ្សេងៗ នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងចំនួន០៧លើក

- បានរៀបចំបែបបទ ផ្តល់សេវា និងអមដំណើរសមាជិកព្រឹទ្ធសភា អញ្ជើញចុះជួបពិភាក្សាការងារជាមួយសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ សំណេះសំណាល សាកសួរសុខទុក្ខប្រជាពលរដ្ឋ ពិនិត្យការដ្ឋានសាងសង់ សម្ពោធសមិទ្ធផលនានា តាមដានការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ក្រោមជាតិ ការអនុវត្តគោលនយោបាយភូមិ ឃុំ មានសុវត្ថិភាព ការអនុវត្តច្បាប់ កែលម្អសេវាសាធារណៈ ពង្រឹងអភិបាលកិច្ចល្អនៅមូលដ្ឋាន និងគោលនយោបាយផ្សេងៗលើគ្រប់វិស័យនៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងចំនួន១៤៧លើក

- ឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភា បានអញ្ជើញចុះជួបសំណេះសំណាល សាកសួរសុខទុក្ខ និងនាំយកអំណោយមនុស្សធម៌ទៅប្រគល់ជូនអាជ្ញាធរមូលដ្ឋាននៅសង្កាត់ព្រែកលៀប សង្កាត់ព្រែកតាសេក សង្កាត់បាក់ខែង សង្កាត់កោះដាច់ សង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ដើម្បីទុកជូនអាជ្ញាធរសង្កាត់ចែកជូនប្រជាពលរដ្ឋដែលងាយរងគ្រោះ

- បានរៀបចំសិក្ខាសាលាស្តីពី ការផ្សព្វផ្សាយចែករំលែកបទពិសោធន៍ការជួយកុមារកម្ពុជាដែលបានបញ្ជូនទៅវះកាត់ និងព្យាបាលជំងឺបេះដូងចំហ ប្រកបដោយជោគជ័យ នៅសាធារណរដ្ឋប្រជាមានិតចិន

- បានទទួលពាក្យបណ្តឹងចំនួន០៥ករណី ធ្វើលិខិតអន្តរាគមន៍ទៅក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីដោះស្រាយចំនួន០២ករណី ទទួលលិខិតឆ្លើយតបការដោះស្រាយពីស្ថាប័នពាក់ព័ន្ធ ចំនួន០២ករណី ធ្វើកំណត់បង្ហាញពាក្យបណ្តឹងចំនួន០២ករណី ឆ្លើយតបទៅម្ចាស់បណ្តឹង ចំនួន០២ករណី និងកំពុងពិនិត្យសិក្សាចំនួន០៣ករណី ព្រមទាំងទទួលឯកសារពាក្យបណ្តឹង

ដែលក្រសួង ស្ថាប័នពាក់ព័ន្ធចម្លងជូនមកគណៈកម្មការដើម្បីជូនជ្រាបបានចំនួន០៥ករណី

- បានទទួលមន្ត្រីរាជការ សិស្ស និស្សិត និងសាធារណជនចូលអានសៀវភៅនៅបណ្ណាល័យព្រឹទ្ធសភាចំនួន៣៥នាក់ ព្រមទាំងបានអនុញ្ញាតឱ្យខ្ចីសៀវភៅចំនួន០៤ក្បាល និងសងវិញចំនួន០៤ក្បាល

- បានផលិតទស្សនាវដ្តីប្រចាំខែមករា ឆ្នាំ២០២១ ចំនួន៨០០ក្បាល។

**៤- មុខងារសហប្រតិបត្តិការអន្តរជាតិ**

- បានរៀបចំទីកន្លែង និងផ្តល់សេវាក្នុងពិធីជំនួបសម្តែងការគួរសមរវាង***សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា*** ជាមួយលោកជំទាវឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាពនៃសាធារណរដ្ឋឥណ្ឌា ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា

- បានរៀបចំទីកន្លែង និងផ្តល់សេវាក្នុងពិធីជំនួបពិភាក្សាការងាររវាងសមាជិកព្រឹទ្ធសភាជាមួយក្រុមអ្នកវិនិយោគទុនមកពីសាធារណរដ្ឋកូរ៉េ

- បានរៀបចំចាត់ចែងជូនសមាជិកព្រឹទ្ធសភា ចូលរួមប្រជុំពិភាក្សាការងារឆ្លើយតបទៅនឹងសំណើរបស់រុស្ស៊ីក្នុងការធ្វើវិសោធនកម្មបទបញ្ជាផ្ទៃក្នុងនៃវេទិកាសភាអាស៊ី-ប៉ាស៊ីហ្វិក(APPF) និងចូលរួមប្រជុំត្រៀមការរៀបចំ ASEPនៅកម្ពុជា

- បានរៀបចំចាត់ចែងជូនសមាជិកព្រឹទ្ធសភា អញ្ជើញដឹកនាំកិច្ចប្រជុំនៃសភាប្រើភាសាបារាំង(APF)ស្តីពី គណៈកម្មការនយោបាយ, គណៈកម្មការអប់រំ ទំនាក់ទំនង និងកិច្ចការវប្បធម៌, បណ្តាញស្ត្រី និងវិសោធនកម្មលក្ខន្តិកៈ តាមប្រព័ន្ធវីដេអូចំនួន០៤លើក

- បានប្រជុំពិនិត្យពិភាក្សាអំពីការត្រៀមចុះអនុស្សរណៈយោគយល់គ្នា(MOU)រវាងគណៈកម្មការទី១ព្រឹទ្ធសភា ជាមួយក្រុមមេធាវីស្ម័គ្រចិត្តសម្តេចតេជោសែន និងសមាគមសាលាត្រាជូស្តីពី កិច្ចសហប្រតិបត្តិការរួមគ្នាជំរុញការងារបណ្តុះបណ្តាលលើកកម្ពស់សមត្ថភាពជំនាញស្រាវជ្រាវ

- បានតាមដាន និងចងក្រងសេចក្តីប្រកាសព័ត៌មាន និងសេចក្តីថ្លែងការណ៍របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិចំនួន០៥ច្បាប់

- បានផលិត និងផ្សព្វផ្សាយព្រឹត្តិបត្រព័ត៌មានកិច្ចការអន្តរជាតិប្រចាំខែមករា ចំនួន០១ច្បាប់

- បានផលិតព័ត៌មានច្បាប់ជាតិ-អន្តរជាតិ និងនយោបាយចំនួន១៣១អត្ថបទ

- បានទទួលសៀវភៅពីអង្គការមូលនិធិអាស៊ីចំនួន២៧៧ក្បាល

- បានទំនាក់ទំនងជាមួយរដ្ឋសភា, ដៃគូភាគីចិន, អង្គការមូលនិធិអាស៊ី, វិទ្យាស្ថានសាន់រ៉ាយស៍, ក្រុមប្រឹក្សាអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា(CDC), ក្រុមហ៊ុនKOHA, ក្រុមហ៊ុនCambodia Hosting,

ក្រសួង ស្ថាប័ននានា ដើម្បីសម្រួលដល់កិច្ចការអន្តរជាតិ និងស្នើសុំអាហារូបករណ៍វគ្គបណ្តុះបណ្តាល ព្រមទាំងការរៀបចំពិធីផ្សេងៗ។

**៥- មុខងារអភិវឌ្ឍន៍ស្ថាប័ន**

- បានទទួលលិខិតចូលចំនួន១,០៥២ច្បាប់ និងបញ្ជូនលិខិតចេញចំនួន៤៤១ច្បាប់
- រៀបចំស្នើសុំជំនួយពីប្រទេសជាមិត្តសម្រាប់នីតិកាលទី៤
- បានស្រាវជ្រាវនិងផ្សព្វផ្សាយអំពីការអនុញ្ញាត និងប្រើប្រាស់វ៉ាក់សាំងកូវីដ-១៩(Covid-19)
- បន្តយកចិត្តទុកដាក់ចូលរួមយុទ្ធនាការប្រយុទ្ធប្រឆាំងជំងឺកូវីដ-១៩(Covid-19)
- បន្តយកចិត្តទុកដាក់ការងាររក្សាអនាម័យ បរិស្ថាន សំរាម សួនច្បារ និងការដាំដើមឈើ ប្រព័ន្ធទឹក លូ ថ្នល់ និងចំណតរថយន្ត ដើម្បីជានាឱ្យមានផាសុកភាព និងបរិស្ថានបៃតង
- បន្តអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាន រដ្ឋបាលអេឡិចត្រូនិច ការប្រើប្រាស់ Zoom ប្រព័ន្ធសំឡេង ការផ្សព្វផ្សាយតាមបណ្តាញសង្គម បណ្ណាល័យ បណ្ណសារដ្ឋានអេឡិចត្រូនិច ការងារព័ត៌មាន ការផលិតវីដេអូ ការបោះពុម្ព និងការថតផ្សព្វផ្សាយអំពីសម័យប្រជុំពេញអង្គព្រឹទ្ធសភាឱ្យបានលឿន ល្អ និងរលូន
- បន្តយកចិត្តទុកដាក់មជ្ឈដ្ឋានដែលនៅខ្សោយ និងសមត្ថភាពផលិតសេវានៅទាប
- បានប្រជុំត្រួតពិនិត្យការអនុវត្តការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- បានប្រជុំពិនិត្យការអនុវត្តការងារ(ការលំបាក ភាពងាយស្រួល និងសំណូមពរ ឬអនុសាសន៍) របស់នាយកដ្ឋានស្រាវជ្រាវថវិកា នៃអគ្គនាយកដ្ឋានស្រាវជ្រាវ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- បានប្រជុំគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- បានប្រជុំស្តីពី ការអនុវត្តកញ្ចប់ថវិការបស់គណៈកម្មការជំនាញ និងក្រុមនានារបស់ព្រឹទ្ធសភាឆ្នាំ២០២១
- បានប្រជុំធ្វូងគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា អំពីរបាយការណ៍ចំណូល ចំណាយថវិកាឆ្នាំ២០២០ និងការបែងចែកកញ្ចប់ថវិកាឆ្នាំ២០២១របស់ព្រឹទ្ធសភា
- បានប្រជុំពិនិត្យ និងពិភាក្សាលើការរៀបចំកសាង និងអនុវត្តថវិកាកម្មវិធីឆ្នាំ២០២១ របស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- បានប្រជុំគណៈកម្មការពិនិត្យលក្ខណៈសម្បត្តិបេក្ខជនដែលស្នើសុំគ្រឿងឥស្សរិយយស (១០%) ជូនមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាមានស្នាដៃការងារសម្រាប់ឆ្នាំ២០២០
- បានប្រជុំពិនិត្យពិភាក្សាលើបេក្ខជនត្រៀមវាយតម្លៃតម្លើងថ្នាក់បៀវត្សតាមវេនជ្រើសរើស និងវេនអតីតភាព ព្រមទាំងនីតិវិធី បែបបទនៃការប្រឡងក្របខណ្ឌមន្ត្រីរាជការនៃអគ្គលេខា-

ធិការដ្ឋានព្រឹទ្ធសភា

- បានប្រជុំគណៈកម្មការវាយតម្លៃស្ថានភាពបាត់បង់សម្បទាវិជ្ជាជីវៈមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

- បានប្រជុំពិនិត្យសេចក្តីព្រាងផែនការសកម្មភាពរួម និងក្របខណ្ឌលទ្ធផលដំណាក់កាលទី៤ (CAP4) និងសូចនាករសមិទ្ធកម្ម (KPIs) ឆ្នាំ២០២១

- បានប្រជុំពិនិត្យគម្រោងកែលម្អសាងសង់អគារថ្មី និងប្រព័ន្ធសន្តិសុខនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

- បានសិក្សាការរៀបចំវិទ្យាស្ថានសភាអាស៊ី(PCA) ដំណាក់កាលបន្ទាប់ពីវិទ្យាស្ថានសភាកម្ពុជា(PIC ) និងការរៀបចំទិន្នន័យច្បាប់ (Legal Database) របស់ព្រឹទ្ធសភា

- បានសិក្សា និងធ្វើបច្ចុប្បន្នភាពគោលការណ៍ និងគោលនយោបាយនានា ឱ្យបានសមស្របនឹងដំណាក់កាលថ្មី

- បានរៀបចំធ្វើតេស្តសមត្ថភាពបុគ្គលិកជាប់កិច្ចសន្យា ចូលក្របខណ្ឌមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

- បានប្រជុំគណៈកម្មការក្រុមប្រឹក្សាវិន័យនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

- បានធ្វើផែនការសកម្មភាពបណ្តុះបណ្តាលរយៈពេល១០ឆ្នាំ របស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា (ឆ្នាំ២០២១-២០៣០)

- បានស្រាវជ្រាវ និងប្រមូលឯកសារពាក់ព័ន្ធ ដើម្បីរៀបចំកសាងគោលនយោបាយអភិវឌ្ឍធនធានមនុស្សរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា (ឆ្នាំ២០២១-២០៣០)

- បានបើកប្រាក់បៀវត្សប្រចាំខែមករា និងប្រាក់ឧបត្ថម្ភផ្សេងៗ ជូនសមាជិកព្រឹទ្ធសភា និងថ្នាក់ដឹកនាំ មន្ត្រីរាជការ បុគ្គលិកជាប់កិច្ចសន្យា ទីប្រឹក្សា ជំនួយការ អ្នកបើកបរ និងនិវត្តជននៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងបានរៀបចំរបាយការណ៍ចំណាយថវិកាកម្មវិធីប្រចាំខែមករា ឆ្នាំ២០២១

- បង្កើន 3E's ដោយយកការសន្សំសំចៃ និងវិចារណកម្មថវិកាជាស្នូល

- បានរៀបចំតបណ្តាញប្រព័ន្ធ (FMIS) បំពាក់សម្ភារ ការប្រើប្រាស់ និងប្រជុំតាមប្រព័ន្ធវីដេអូ

- បានធ្វើប័ណ្ណសម្គាល់ខ្លួន និងប័ណ្ណចេញ-ចូលក្នុងបរិវេណព្រឹទ្ធសភាចំនួន១៤ប័ណ្ណ

- បានរៀបចំលិខិតបទដ្ឋានគតិយុត្តផ្សេងៗចំនួន៤៧ច្បាប់

- បានបើកវគ្គបណ្តុះបណ្តាលក្នុងប្រទេសចំនួន០៧វគ្គ មានសិក្ខាកាមចូលរួមចំនួន១០៣នាក់

- ការអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភារួមមាន៖ ចំណេះដឹង ជំនាញ ភាសាបរទេស ការដឹកនាំ/គ្រប់គ្រង និងបច្ចេកវិទ្យាព័ត៌មាន

- បានទទួលអាហារូបករណ៍ចំនួន២៨កន្លែង លើជំនាញ Digital Skill Essential នៅវិទ្យាស្ថានជាតិប្រៃសណីយ៍ ទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន(NIPTICT)

- បានជួសជុល និងគូសគំនូសចំណតរថយន្ត និងសញ្ញាចរាចរណ៍ នៅតាមចំណតនានាក្នុងបរិវេណព្រឹទ្ធសភា

- បានកែលម្អសួនច្បារ ដាំដើមផ្កាចំរុះពណ៌ថ្មីៗ និងរុក្ខជាតិផ្សេងៗចំនួន១៨លើក ព្រមទាំងកាត់តម្រឹមស្មៅ និងផ្កានានាចំនួន១២ប្លង់

- បានជួសជុល កែលម្អហេដ្ឋារចនាសម្ព័ន្ធ អគារ បណ្តាញទឹក ត្រួតពិនិត្យដំណើរយន្ត និងផ្លាស់ប្តូរគ្រឿងអគ្គិសនី គ្រឿងអេឡិចត្រូនិច គ្រឿងសង្ហារឹម បិទលេខកូដសម្ភារសារពើភ័ណ្ឌ ព្រមទាំងបានប្រគល់សម្ភារការិយាល័យជូនអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន២៤៦គ្រឿង/លើក

- បានចុះត្រួតពិនិត្យ តាមដានប្រព័ន្ធ Network Internet Wi-Fi, ជួសជុលម៉ាស៊ីនកុំព្យូទ័រ Ipad Smart Phone, ដាក់កម្មវិធីកម្ចាត់មេរោគUpdate Files Antivirus និងបញ្ចូលកម្មវិធី Unicode ព្រមទាំងបានដោះស្រាយបញ្ហាផ្សេងៗដែលពាក់ព័ន្ធនឹងជំនាញបច្ចេកវិទ្យាព័ត៌មានចំនួន១៦៧គ្រឿង។ បានបញ្ចូលព័ត៌មានស្តីពី សកម្មភាពរបស់ថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា និងថ្នាក់ដឹកនាំនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាលើគេហទំព័រព្រឹទ្ធសភាចំនួន៣៧ប្រធានបទ

- បានបញ្ចូលឯកសារ សៀវភៅច្បាប់ សៀវភៅបោះពុម្ពដោយអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងជំនាញផ្សេងៗតាម E-Library & NAS ចំនួន២៧ក្បាល

- បានប្រើប្រាស់ Mail ជាមធ្យោបាយសម្រាប់ដំណើរការចរន្តឯកសារផ្ទៃក្នុងនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

- បានធ្វើសម្រង់ស្ថិតិ បទបង្ហាញ របាយការណ៍ស្តីពី លទ្ធផលការងារព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែមករា ឆ្នាំ២០២១ ព្រមទាំងបានផ្សព្វផ្សាយទៅតាមអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងក្រសួង ស្ថាប័ននានា។

**II-លទ្ធផលការងារគាំទ្រលើមុខងារទាំង៥៖**

- បានពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន៤៦៨ច្បាប់

- បានរៀបចំចាត់ចែង ជូនថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ជួបពិភាក្សាការងារ ចូលរួមកិច្ចប្រជុំ និងពិធីផ្សេងៗចំនួន១៥លើក

- បានតុបតែងលម្អ និងតាំងពិព័រណ៍រូបភាពចំនួន០៩លើក

- បានផ្ញើលិខិតបេសកកម្មជូនសមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន១៣ច្បាប់ ស្មើនឹង៥២នាក់

- បានផ្តល់សេវាថវិកាជូនថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងបានទូទាត់ការចំណាយផ្សេងៗចំនួន៣៧៩លើក

- បានរៀបចំសម្អាត តុបតែងលម្អសាលប្រជុំ ផ្គត់ផ្គង់សម្ភារប្រើប្រាស់ បម្រើសេវាភេសជ្ជៈ អាហារសម្រន់ក្នុងកិច្ចប្រជុំ និងពិធីផ្សេងៗចំនួន៣៥លើក មានអ្នកចូលរួមចំនួន១,២៧៧នាក់

- បានផ្គត់ផ្គង់វត្ថុអនុស្សាវរីយ៍ គ្រឿងបរិក្ខារ ប្រេងឥន្ធនៈ សម្ភារអនាម័យ សម្ភារការិយាល័យ ភេសជ្ជៈ និងអាហារសម្រន់សម្រាប់បម្រើដល់កិច្ចប្រជុំ និងជូនគ្រប់អង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន៨២សំណើ

- បានចុះសួរសុខទុក្ខមន្ត្រីរាជការលំហែមាតុភាព មានជំងឺ និងនិវត្តជននៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន០៣លើក

- បានចែកម៉ាស់ចំនួន២០០ប្រអប់ ជូនគ្រប់អង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

- បានចែកទឹកអាល់កុលលាងដៃសម្លាប់មេរោគចំនួន១៩០លីត្រ តាមការស្នើសុំរបស់អង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

- បានថតចម្លងឯកសារចំនួន៩,២៩៩ច្បាប់ និងចងក្រងធ្វើជាសៀវភៅចំនួន១១៦ក្បាល អស់ក្រដាសចំនួន២២,២២៩សន្លឹក

- បានផ្តល់សេវាដឹកជញ្ជូនសម្រាប់ថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចុះបំពេញបេសកកម្មនៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុង ចំនួន១២៦លើក ស្មើនឹង១៥១នាក់

- បានផលិតព្រឹត្តិបត្រព័ត៌មានថវិកា និងសេដ្ឋកិច្ចចំនួន០២ច្បាប់

- បានផលិតខ្សែវីដេអូព័ត៌មានស្តីពី សកម្មភាពការងាររបស់ថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា និងថ្នាក់ដឹកនាំនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន០៣លើក

- បានថត និងផ្សព្វផ្សាយព័ត៌មានស្តីពី សកម្មភាពការងាររបស់ថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា និងថ្នាក់ដឹកនាំនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា តាមប្រព័ន្ធTwitter, Youtube, Facebook, និង Telegramចំនួន១,២៥០លើក

- បានប្រមូល ដកស្រង់ ចងក្រង និងផ្សព្វផ្សាយព័ត៌មានសង្ខេបប្រចាំថ្ងៃសរុបចំនួន៥៩លើក និងទស្សនព័ត៌មានប្រចាំថ្ងៃចំនួន២៦លើក

- បានទទួល និងរៀបចំសៀវភៅច្បាប់ ឯកសារ និងទស្សនាវដ្តីចំនួន២២៣ក្បាល និងព្រឹត្តិបត្រ កាសែតAKPចំនួន១២០ច្បាប់ ព្រមទាំងបានបោះត្រា ចុះបញ្ជីសៀវភៅ ដាក់លេខកូដ

សៀវភៅ បិទប័ណ្ណខ្ចី និងសងសៀវភៅចំនួន៦៥៨ក្បាល

- បានការពារសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ក្នុងកិច្ចប្រជុំ និងពិធីផ្សេងៗដោយប្រើប្រាស់កម្លាំងសន្តិសុខផ្ទៃក្នុងចំនួន១៩លើក។

**III-ទិសដៅការងារខែកុម្ភៈ ឆ្នាំ២០២១**

***ដំណើរឆ្ពោះទៅកាន់មូលដ្ឋានរបស់ព្រឹទ្ធសភា ក្នុងរយៈពេលវិស្សមកាល ចាប់ពីថ្ងៃទី២៥ ខែមករា ដល់ថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២១***

-ត្រៀមផ្តល់សេវាជូនសមាជិកព្រឹទ្ធសភា ឱ្យបានល្អប្រសើរ និងគ្រប់ជ្រុងជ្រោយក្នុងដំណើរចុះទៅមូលដ្ឋាន និងជួបសវនាការជាមួយក្រសួង ស្ថាប័ននានា

-ត្រៀមសហការធ្វើរបាយការណ៍ចន្លោះសម័យប្រជុំលើកទី៦ និងលើកទី៧ នីតិកាលទី៤ ឱ្យបានទាន់ពេលវេលា និងល្អប្រសើរ។

**១- មុខងារនីតិកម្ម**

- ត្រៀមរៀបចំប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា និងសម័យប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ នីតិកាលទី៤៖

១-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឱ្យក្រុមហ៊ុនស្ទេថេក ខូ អិលធីឌី សម្រាប់គម្រោងអភិវឌ្ឍខ្សែបណ្តាញបញ្ជូនអគ្គិសនី តង់ស្យុង៥០០គីឡូវ៉ុល ពីរាជធានីភ្នំពេញទៅកាន់ព្រំដែនកម្ពុជា-ឡាវ

២-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឱ្យក្រុមហ៊ុន ស្ទេថេក ខូ អិលធីឌី សម្រាប់គម្រោងអភិវឌ្ឍខ្សែបណ្តាញបញ្ជូនអគ្គិសនី តង់ស្យុង៥០០គីឡូវ៉ុល ពីខេត្តបាត់ដំបងទៅកាន់ព្រំដែនកម្ពុជា-ថៃ

៣-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឱ្យក្រុមហ៊ុនធាយណា ណេសិនណល ហេវី ម៉ាស៊ីនណឺរី ខបភើរេសិន សម្រាប់គម្រោងអភិវឌ្ឍវារីអគ្គិសនីស្ទឹងតាតៃ លើអានុភាព ១៥០មេហ្គាវ៉ាត់ ខេត្តកោះកុង

៤-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឱ្យក្រុមហ៊ុនអគ្គិសនីវៀតណាម នៃសាធារណរដ្ឋសង្គមនិយមវៀតណាម។

**២- មុខងារតាមដានការអនុវត្តច្បាប់ និងគោលនយោបាយនានា**

-ត្រៀមសហការ និងសម្របសម្រួលការងារជូនថ្នាក់ដឹកនាំ និងសមាជិកព្រឹទ្ធសភាជួបសវនាការ ពិភាក្សាការងារជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនានា និងការចុះបេសកកម្ម នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងនានា៖

+គណៈកម្មការទី១ អញ្ជើញចុះបេសកកម្មទៅខេត្តកំពង់ធំ ខេត្តព្រះវិហារ និង

ខេត្តឧត្តរមានជ័យ (ថ្ងៃទី២១ -២៧ ខែមីនា ឆ្នាំ២០២១)

+គណៈកម្មការទី២ អញ្ជើញចុះបេសកកម្មទៅខេត្តសៀមរាប (ថ្ងៃទី០៣ -០៦ ខែមីនា ឆ្នាំ២០២១)

+គណៈកម្មការទី៣ អញ្ជើញជួបពិភាក្សាការងារជាមួយថ្នាក់ដឹកនាំនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (ថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២១) និងថ្នាក់ដឹកនាំនៃក្រសួងបរិស្ថាន (ថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២១) ព្រមទាំងអញ្ជើញចុះបេសកកម្មទៅខេត្តកំពង់ស្ពឺ (ថ្ងៃទី២៦ ខែមីនា- ថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២១)

+គណៈកម្មការទី៤ អញ្ជើញចុះបេសកកម្មទៅខេត្តកោះកុង (ថ្ងៃទី១៧-១៩ ខែកុម្ភៈ ឆ្នាំ២០២១)

+គណៈកម្មការទី៥ អញ្ជើញជួបពិភាក្សាការងារជាមួយអគ្គនាយកអន្តោប្រវេសន៍នៃក្រសួងមហាផ្ទៃ (ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២១) ព្រមទាំងអញ្ជើញចុះបេសកកម្មទៅខេត្តកំពត ខេត្តកែប ខេត្តព្រះសីហនុ និងខេត្តតាកែវ (ថ្ងៃទី២៨ ខែកុម្ភៈ - ថ្ងៃទី០៥ ខែមីនា ឆ្នាំ២០២១)

+គណៈកម្មការទី៨ អញ្ជើញចុះបេសកកម្មទៅខេត្តរតនគិរី និងខេត្តមណ្ឌលគិរី។

**៣- មុខងារតំណាង**

-ត្រៀមរៀបចំជូនថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា អញ្ជើញចុះបំពេញការងារនៅមូលដ្ឋាន ចូលរួមកិច្ចប្រជុំ និងពិធីផ្លូវការផ្សេងៗនៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងនានាៈ

+ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ អញ្ជើញចុះរៀបចំវេទិកាថ្នាក់ស្រុក នៅខេត្តកំពង់ចាម (ថ្ងៃទី០២ -០៥ ខែកុម្ភៈ ឆ្នាំ២០២១)

+ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៤ អញ្ជើញចុះរៀបចំពិធីសំណេះសំណាល នៅខេត្តបាត់ដំបង និងខេត្តប៉ៃលិន (ថ្ងៃទី០៩ -១៣ ខែមីនា ឆ្នាំ២០២១)

+ក្រុមសមាជិកាព្រឹទ្ធសភា អញ្ជើញចុះរៀបចំពិធីសំណេះសំណាល នៅខេត្តកំពង់ធំ។

**៤- មុខងារសហប្រតិបត្តិការអន្តរជាតិ**

-ត្រៀមរៀបចំពិធីជំនួបសវនាការរវាងថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា ជាមួយគណៈប្រតិភូជាតិ/អន្តរជាតិ និងអង្គទូតនានា

-ត្រៀមរៀបចំ ASEP/ASEM ឆ្នាំ២០២១

-ត្រៀមចូលរួមប្រជុំក្រុមប្រឹក្សាភិបាលវិទ្យាស្ថានសភាកម្ពុជា(PIC) និងការត្រៀមរៀបចំវិទ្យាស្ថានសភាអាស៊ី(PCA)

-បន្តសកម្មភាពសហប្រតិបត្តិការជាមួយដៃគូនានា ដើម្បីអនុវត្តយុទ្ធសាស្ត្រថវិកាតិច សកម្មភាពច្រើន។

## ៥- មុខងារអភិវឌ្ឍន៍ស្ថាប័ន

-បន្តប្រជុំគណៈកម្មការគោលការណ៍ និងគោលនយោបាយនានារបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-ត្រៀមធនធានមនុស្ស និងឯកសារ ដើម្បីត្រៀមចុះអនុស្សរណៈយោគយល់គ្នា(MOU) រវាងគណៈកម្មការទី១ព្រឹទ្ធសភា ជាមួយក្រុមមេធាវីស្ម័គ្រចិត្តសម្តេចតេជោសែន និងសមាគមសាលាត្រាជូស្តីពី កិច្ចសហប្រតិបត្តិការរួមគ្នាជំរុញការងារបណ្តុះបណ្តាលលើកកម្ពស់សមត្ថភាពជំនាញស្រាវជ្រាវ

-នាយកដ្ឋានព័ត៌មានវិទ្យា នាយកដ្ឋានស្រាវជ្រាវកិច្ចការអន្តរជាតិ នាយកដ្ឋានអភិវឌ្ឍន៍ធនធានមនុស្ស ត្រូវបន្តទំនាក់ទំនងជាមួយដៃគូអភិវឌ្ឍរបស់ខ្លួន (ក្រុមហ៊ុនHuawei វិទ្យាស្ថានជាតិការទូត និងដៃគូបណ្តុះបណ្តាលនានាៗល។)

-អគ្គនាយកដ្ឋាន នាយកដ្ឋាន និងគ្រប់អង្គភាពចំណុះទាំងអស់ ត្រូវបង្កើន និងពង្រឹងយន្តការការងារតាមប្រព័ន្ធOnline ដើម្បីជានាគុណភាព ប្រសិទ្ធភាព ប្រសិទ្ធផល និងស័ក្តិសិទ្ធិភាពជូនស្ថាប័នឱ្យបានល្អប្រសើរ

-បន្តកសាង និងធ្វើបច្ចុប្បន្នភាព គោលការណ៍ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្តបម្រើឱ្យការគ្រប់គ្រងក្នុងបរិបទកែទម្រង់រដ្ឋបាលសាធារណៈ និងហិរញ្ញវត្ថុសាធារណៈ

-ត្រៀមរៀបចំធ្វើបច្ចុប្បន្នភាពគោលការណ៍ហិរញ្ញវត្ថុសំខាន់ៗ និងថវិកាតាមកម្មវិធីលើមូលដ្ឋានរចនាសម្ព័ន្ធថ្មីរបស់អគ្គនាយកដ្ឋានទាំង៤

-បន្តសហការជាមួយក្រុមការងារ FMIS របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងការប្រើប្រាស់និងបំពាក់សម្ភារប្រជុំតាមប្រព័ន្ធវីដេអូ

-ត្រៀមធ្វើជំរឿនសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ ធនធានមនុស្ស និងតម្រូវការផ្សេងៗ

-បន្តថែរក្សាហេដ្ឋារចនាសម្ព័ន្ធ និងបរិស្ថាននៅក្នុងបរិវេណព្រឹទ្ធសភា

-បង្កើនការគ្រប់គ្រងអគារ និងសារពើភ័ណ្ឌ ការគ្រប់គ្រងសន្តិសុខ សណ្តាប់ធ្នាប់ អនាម័យការសន្សំសំចៃទឹក ភ្លើង និងការគ្រប់គ្រងការប្រើប្រាស់ Internet

-ការចាប់ផ្តើមរៀបចំប្រព័ន្ធ Website/Webpage ក្នុងកម្រិតអគ្គនាយកដ្ឋាន គណៈកម្មការនិងក្រុមនានា

-បង្កើនការបញ្ចូលប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន(ICT) គ្រប់វិស័យនៃការងាររបស់ស្ថាប័ន

-បង្កើនគុណភាពនៃការថត និងផ្សព្វផ្សាយអំពីសម័យប្រជុំពេញអង្គព្រឹទ្ធសភា

-បន្តកសាងប្រព័ន្ធគ្រប់គ្រងទិន្នន័យ គ្រប់គ្រងព័ត៌មាន គ្រប់គ្រងរដ្ឋបាល កម្មវិធីបណ្ណសារអេឡិចត្រូនិច និងបណ្ណាល័យអេឡិចត្រូនិច ត្រូវបន្តសហការយ៉ាងសកម្មជាមួយភាគីចិន

-ត្រៀមចូលរួមពិធីបុណ្យជាតិសំខាន់ៗ។

## IV-**សេចក្តីសន្និដ្ឋាន**

ក្នុងខែមករានេះ ថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានខិតខំប្រឹងប្រែងយ៉ាងយកចិត្តទុកដាក់គ្រប់ការដ្ឋាន ដើម្បីបញ្ចប់ការងារដែលនៅសេសសល់ពីឆ្នាំ២០២០។ម្យ៉ាងទៀតនេះ ជាជំហានដំបូងដើមឆ្នាំ សម្រាប់អនុវត្តផែនការប្រតិបត្តិឆ្នាំ២០២១ តាមក្របខណ្ឌយុទ្ធសាស្ត្រសម្រាប់ពង្រឹងសមត្ថភាពព្រឹទ្ធសភា។ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា នៅតែបន្តផ្តល់សេវាការងារជាអាទិភាពលើមុខងារស្នូលទាំង៣របស់ខ្លួនប្រព្រឹត្តទៅតាមការគ្រោងទុក ដោយបានរៀបចំ និងចាត់ចែងការប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន០១លើក បានដោយរលូន។ ទន្ទឹមនឹងនេះ បានអមដំណើរសមាជិកព្រឹទ្ធសភា ចុះបំពេញការងារតាមមូលដ្ឋាន ដើម្បីសួរសុខទុក្ខ ដោះស្រាយបញ្ហាប្រឈម និងសំណូមពរនានារបស់ប្រជាពលរដ្ឋ នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងនានា បានយ៉ាងល្អប្រសើរ។ ចំពោះកិច្ចសហប្រតិបត្តិការជាមួយដៃគូនានា បានត្រៀមខ្លួនជាស្រេច ដើម្បីចុះអនុស្សរណៈយោគយល់គ្នា(MOU) និងបានរៀបចំចាត់ចែងការប្រជុំអន្តរជាតិនានាតាមប្រព័ន្ធវីដេអូ។ ក្រៅពីការងារជាអាទិភាពខាងលើអគ្គលេខាធិការដ្ឋាន នៅតែបន្តយកចិត្តទុកដាក់បណ្តុះបណ្តាលលើកកម្ពស់សមត្ថភាព និងជំនាញរបស់មន្ត្រីរាជការឱ្យកាន់តែមានគុណភាព និងប្រសិទ្ធភាព។

អគ្គលេខាធិការដ្ឋាន បានយកចិត្តទុកដាក់ជំហានបន្ទាប់របស់វិទ្យាស្ថានសភាកម្ពុជា(PIC) ដែលនឹងចាប់ដំណើរការជាវិទ្យាស្ថានសភាអាស៊ី(PCA) នៅពេលខាងមុខ។ ក្នុងឆ្នាំថ្មី អាទិភាពនៃការពង្រឹងមុខងារទាំង៥ និងពន្ទឺថ្មីតាមកិច្ចពិគ្រោះយោបល់ ថ្ងៃទី១១ ខែមករា និងស្មារតីប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ថ្ងៃទី១៥ ខែមករា ព្រឹទ្ធសភាត្រូវខិតខំដើរទៅមុខ តាមរយៈការបង្កើនសមត្ថភាពស្រាវជ្រាវ និងប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានក្នុងការងារឱ្យបានជាអតិបរមា ព្រមទាំងសមត្ថភាពភាសាបរទេស និងជំនាញផ្សេងៗទៀត។

ថ្ងៃ[illegible] ខែមាឃ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ, ថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០២១

**អគ្គលេខាធិការ**

អ៊ុំ_សារិទ្ធ